# ព្រះរាជក្រម

នស/រកម/១១២០/០៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម

**មាត្រា១ .-**

អនុម័តយល់ព្រមលើពិធីសារខណ្ឌសីមានិងបោះបង្គោលព្រំដែនគោក រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅរដ្ឋធានីហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

**មាត្រា៣ .-**

ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់។

ថ្ងៃពុធ ១០កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២០

ពាស.៤០១១.១២៩៥

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**



Media from www.moj.gov.kh resource from www.ocm.gov.kh

# ពិធីសារ
# ខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក រវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ក្រោយមកហៅថា "ភាគីទាំងពីរ")

-យោងតាមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៨៥ (ក្រោយមកហៅថា សន្ធិសញ្ញាឆ្នាំ១៩៨៥) សន្ធិសញ្ញាបំពេញបន្ថែម រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ (ក្រោយមកហៅថា សន្ធិសញ្ញាឆ្នាំ២០០៥) អនុសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការកំណត់ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ និងសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ (ក្រោយមកហៅថា សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩)។

ដើម្បីកត់ត្រាលទ្ធផលដែលទទួលបានក្នុងការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក រវាងប្រទេសទាំងពីរ (ប្រមាណជា ៨៤%) ភាគីទាំងពីរបានចុះហត្ថលេខាលើពិធីសារ រួមមានខ្លឹមសារដូចខាងក្រោម៖

## ផ្នែកទី ១
## បទកំណត់រួម
### ប្រការ ១ ៖ ឯកសារមូលដ្ឋាននៃការងារខណ្ឌសីមា និងបោះបង្គោលព្រំដែន

-អនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការកែសម្រួលខ្សែព្រំដែនគោក នៅតំបន់ដែលនៅសេសសល់មួយចំនួន រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ (ក្រោយមកហៅថា MOU ឆ្នាំ២០១១)។

-កំណត់ហេតុកិច្ចប្រជុំទ្វេភាគីចំនួន ៩ កំរិត ស្មើនឹង១៩៩ កំណត់ហេតុ ក្នុងនោះ ៖ (១)-កំណត់ហេតុកិច្ចប្រជុំពេញអង្គនៃគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកចំនួន៥ (២)-កំណត់ហេតុកិច្ចប្រជុំគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកចំនួន៣៥ (៣)-កំណត់ហេតុកិច្ចប្រជុំអនុគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកចំនួន៧ (៤)-កំណត់ហេតុរបស់ក្រុមជំនាញនៃគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក



Media from www.moj.gov.kh resource from www.ocm.gov.kh

ចំនួន៣២ (៥)-កំណត់ហេតុក្រុមសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគម្រោងផលិតផែនទីឋានលេខាព្រំដែនគោកកម្ពុជា-វៀតណាម (CMG) ចំនួន ២៥ (៦)-កំណត់ហេតុក្រុមជំនាញចម្រុះព្រំដែនគោកចំនួន៦ (៧)-កំណត់ហេតុកិច្ចប្រជុំនៃក្រុមការងារការិយាល័យ ដើម្បីត្រួតពិនិត្យការគូសចម្លងខ្សែព្រំដែនគោកចំនួន១៥ (៨)-កំណត់ហេតុក្រុមការងារពិសេសព្រំដែនគោកចំនួន៥៦ និង(៩)-កំណត់ហេតុក្រុមជំនាញGPSចំនួន១៨ ។

**ប្រការ ២ ៖ សេចក្តីរួម អំពីខ្សែព្រំដែន**

១-ចំណុចចាប់ផ្តើមនៃខ្សែព្រំដែនគោកកម្ពុជា-វៀតណាម គឺជាចំណុចប្រសព្វខ្សែព្រំដែន រវាង ០៣ ប្រទេស គឺព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវក្រោយមកហៅកាត់ថា "ចំណុចប្រសព្វខ្សែព្រំដែន រវាង ០៣ ប្រទេស កម្ពុជា-វៀតណាម-ឡាវ" ត្រូវបានកំណត់នៅក្នុង "អនុសញ្ញារវាងព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការកំណត់ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ និងត្រូវបានពិពណ៌នាលម្អិត ក្នុងផ្នែកទី២ នៃពិធីសារនេះ។

២-ចំណុចបញ្ចប់នៃខ្សែព្រំដែនគោកកម្ពុជា-វៀតណាម ជាទីតាំងបង្គោលព្រំដែនលេខ៣១៤ ត្រូវបានកំណត់ក្នុងវាក្យខណ្ឌ២ ប្រការ១ នៃសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩ ត្រូវបានពិពណ៌នាលម្អិត ក្នុងផ្នែកទី២ នៃពិធីសារនេះ។ ចំណុចនេះ ក៏ជាចំណុចចាប់ផ្តើមនៃខ្សែព្រំដែនសមុទ្ររបស់ប្រទេសទាំងពីរ។

៣-សរុបប្រវែងខ្សែព្រំដែនកម្ពុជា-វៀតណាម ដែលភាគីទាំងពីរបានបញ្ចប់ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនបានចំនួន ១០៤៤.៩៨៥ គ.ម (មួយពាន់សូន្យរយសែសិបបួនគីឡូម៉ែត្រ និងប្រាំបួនរយប៉ែតសិបប្រាំម៉ែត្រ) ក្នុងនោះខ្សែព្រំដែនគោកមានប្រវែង ៤៨៨.១៤៨ គ.ម(បួនរយប៉ែតសិបប្រាំបីគីឡូម៉ែត្រ និងមួយរយសែសិបប្រាំបីម៉ែត្រ) ហើយខ្សែព្រំដែនតាមផ្លូវទឹកមានប្រវែង ៥៥៦.៨៣៧ គ.ម (ប្រាំរយហាសិបប្រាំមួយគីឡូម៉ែត្រ និងប្រាំបីរយសាមសិបប្រាំពីរម៉ែត្រ)។

៤-ទិសដើរនៃខ្សែព្រំដែន ទីតាំងបង្គោលព្រំដែន បង្គោលព្រំដែនបំពេញបន្ថែម បង្គោលតម្រុយព្រំដែន និងចំណុចពិសេសត្រូវបានពិពណ៌នាលម្អិតនៅផ្នែកទី២ នៃពិធីសារនេះ និងត្រូវបានបង្ហាញនៅលើ "ផែនទីឋានលេខាព្រំដែនកម្ពុជា-វៀតណាម" មាត្រដ្ឋាន ១/២៥.០០០ ចុះហត្ថលេខានៅថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៩(ក្រោយមកហៅកាត់ថា "ផែនទីព្រំដែន") ឧបសម្ព័ន្ធ១ អមពិធីសារនេះ។



Media from www.moj.gov.kh resource from www.ocm.gov.kh

**ប្រការ ៣ ៖ អំពីបង្គោលព្រំដែន**

**១-ប្រភេទបង្គោលព្រំដែន៖**

១.១-បង្គោលព្រំដែនរួមមាន ០៣ ប្រភេទគឺ៖ បង្គោលព្រំដែន បង្គោលព្រំដែនបំពេញបន្ថែម និងបង្គោលតម្រុយព្រំដែន

១.២-បង្គោលព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែមមាន៖ បង្គោលទោល បង្គោលភ្លោះមានលេខរៀងដូចគ្នា និងបង្គោលត្រីមានលេខរៀងដូចគ្នា

១.២.១-បង្គោលព្រំដែនទោល ជាបង្គោលព្រំដែន ដែលបោះលើខ្សែព្រំដែន ហើយមុខបង្គោលនៅទិសខាងប្រទេសណាមានសរសេរឈ្មោះនៃប្រទេសនោះ ជាភាសាខ្មែរ ឬជាភាសាវៀតណាម

១.២.២-បង្គោលព្រំដែនភ្លោះ មានលេខរៀងដូចគ្នា ធ្វើឡើងដោយពីរបង្គោល បោះនៅលើច្រាំងសងខាងផ្លូវទឹកនៃភាគីទាំងពីរ។ បង្គោលបោះនៅលើដែនដីរបស់ប្រទេសណា មានសរសេរឈ្មោះប្រទេសនោះនៅលើមុខទាំងពីរនៃបង្គោល ជាភាសាខ្មែរ ឬភាសាវៀតណាម

១.២.៣-បង្គោលព្រំដែនត្រី មានលេខរៀងដូចគ្នា ធ្វើឡើងដោយបង្គោលបី បោះនៅលើច្រាំងផ្លូវទឹកនៃភាគីទាំងពីរ នៅត្រង់ចំណុចប្រសព្វ (ឬចំណុចបំបែក) នៃផ្លូវទឹកព្រំដែនជាមួយនឹងផ្លូវទឹកក្នុងដែនដី។ បង្គោលបោះនៅលើដែនដីរបស់ប្រទេសណាមានសរសេរឈ្មោះប្រទេសនោះ នៅលើមុខទាំងពីរនៃបង្គោលជាភាសាខ្មែរ ឬភាសាវៀតណាម។

**២-ស្តីពីលេខរៀងបង្គោលព្រំដែន៖**

២.១-បង្គោលព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែម៖

២.១.១-បង្គោលព្រំដែនត្រូវបានដាក់លេខរៀងចាប់ពីទិសខាងជើង ចុះទៅទិសខាងត្បូង តាមលេខលំដាប់កើនឡើងនៃចំនួនគត់ធម្មជាតិម្តងមួយៗចាប់ពីលេខ១ ដល់លេខ៣១៤។ បង្គោលព្រំដែនភ្លោះមានលេខរៀងដូចគ្នា មានសរសេរបន្ថែមលេខ(១) ឬលេខ(២) នៅខាងក្រោយលេខលំដាប់ និងបង្គោលព្រំដែនត្រីមានលេខរៀងដូចគ្នាដែរ ជាលេខលំដាប់ត្រូវបានសរសេរបន្ថែមលេខ(១) ឬលេខ(២) ឬលេខ(៣) នៅពីក្រោយលេខលំដាប់នោះ។

២.១.២-លេខរៀងបង្គោលព្រំដែនបំពេញបន្ថែម បង្ហាញដោយលេខប្រភាគ ហើយលេខភាគយកជាលេខបង្គោលព្រំដែននៅខាងមុខ លេខភាគបែងជាលេខកើនតាមលំដាប់ រាប់ចាប់ពីលេខ១។ លេខរៀងបង្គោលព្រំដែនបំពេញបន្ថែមភ្លោះ ដែលមានលេខរៀងដូចគ្នា មានសរសេរថែមលេខ(១) ឬលេខ(២) នៅពីក្រោយលេខភាគបែងនោះ។ រីឯបង្គោលព្រំដែនបំពេញបន្ថែមត្រី មានលេខរៀងដូចគ្នា មានសរសេរថែមលេខ(១) លេខ(២) ឬលេខ(៣) នៅពីក្រោយលេខភាគបែងនោះ។



Media from www.moj.gov.kh resource from www.ocm.gov.kh

២.១.៣-បង្គោលព្រំដែនភ្លោះ មានលេខរៀងដូចគ្នា ត្រូវបានបោះនៅលើច្រាំងសងខាងនៃផ្លូវទឹក និងនៅលើបង្គោលត្រូវបានសរសេរបន្ថែមលេខ(១) បោះនៅលើច្រាំងនៃផ្លូវទឹកខាងកម្ពុជា និងនៅលើបង្គោលត្រូវបានសរសេរបន្ថែមលេខ(២) បោះនៅលើច្រាំងនៃផ្លូវទឹកខាងវៀតណាម។

ចំពោះបង្គោលភ្លោះមានលេខរៀងដូចគ្នា បោះនៅត្រង់ចំណុចប្តូរទិសពីលើគោក ចុះទៅព្រំដែនផ្លូវទឹក និងបញ្ច្រាស់មកលើគោកវិញ នឹងមានបង្គោលមួយត្រូវបានបោះនៅលើខ្សែព្រំដែន។ ដោយឡែកបង្គោលព្រំដែនភ្លោះមានលេខរៀង ២១៦ (១) និងលេខ ២១៦ (២) ត្រូវបានបោះនៅលើខ្សែព្រំដែនទាំងពីរ។ រាល់បង្គោលភ្លោះដែលបោះនៅលើខ្សែព្រំដែន មានផ្ទៃមុខបង្គោលដូចមុខបង្គោលទោល។

២.១.៤-បង្គោលព្រំដែនត្រីមានលេខរៀងដូចគ្នា បោះនៅត្រង់តំបន់រវាងព្រំដែនផ្លូវទឹកបែកជាបី និងផ្លូវទឹកខាងក្នុងដែនដី ត្រូវបានដាក់លេខរៀងតាមទិសទ្រនិចនាឡិកា ហើយបង្គោលមានសរសេរបន្ថែមលេខ(១) បោះនៅលើច្រាំងនៃព្រំដែនផ្លូវទឹករបស់ភាគីដែលគ្មានផ្លូវទឹកក្នុងដែនដី និងពីរបង្គោលទៀតមានសរសេរបន្ថែមលេខ(២)និងលេខ(៣) បោះនៅលើច្រាំងនៃព្រំដែនផ្លូវទឹករបស់ភាគីដែលមានផ្លូវទឹកក្នុងដែនដី។

២.២-ចំពោះបង្គោលតម្រុយព្រំដែន៖ ត្រូវបានដាក់លេខរៀងតាមលេខលំដាប់កើនឡើងនៃចំនួនគត់ធម្មជាតិចាប់ផ្តើមពីលេខ១ នៅតាមកំណាត់ព្រំដែននីមួយៗដែលមានបោះបង្គោលតម្រុយព្រំដែន។

**៣.ការផលិត និងសាងសង់បង្គោលព្រំដែន៖**

៣.១-បង្គោលព្រំដែន៖ ធ្វើដោយថ្មក្រានីត នៅលើផ្ទៃមុខបង្គោលមានឆ្លាក់អក្សរឈ្មោះប្រទេស លេខរៀងបង្គោល ឆ្នាំផលិតបង្គោល និងមាន០៣ ប្រភេទដូចខាងក្រោម៖

៣.១.១-បង្គោលព្រំដែនប្រភេទA គឺជាបង្គោលដែលមានទំហំធំជាងគេ ត្រូវបានបោះនៅតាមច្រកទ្វារព្រំដែនអន្តរជាតិ ហើយមានភ្ជាប់និមិត្តសញ្ញាជាតិនៃប្រទេសទាំងពីរ ។

៣.១.២-បង្គោលព្រំដែនប្រភេទB និងប្រភេទC គឺជាបង្គោលដែលមានទំហំដូចគ្នា ហើយតូចជាងបង្គោលព្រំដែនប្រភេទA ។ បង្គោលប្រភេទB ត្រូវបានបោះនៅភូមិសាស្ត្រមិនលិចទឹក នៅរដូវភ្លៀង និងបង្គោលព្រំដែនប្រភេទC ត្រូវបានបោះនៅភូមិសាស្ត្រលិចទឹកនៅរដូវភ្លៀង និងមានផ្នែកខឿននៃបង្គោលសាងសង់ខ្ពស់។

៣.២-បង្គោលព្រំដែនបំពេញបន្ថែម៖ ធ្វើពីបេតុងសរសៃដែក នៅលើមុខបង្គោលមានឆ្លាក់ឈ្មោះប្រទេស និងលេខរៀងបង្គោល។ ដោយឡែកបង្គោលព្រំដែនបំពេញបន្ថែមទោល មានលេខរៀងសេស និងបង្គោលព្រំដែនបំពេញបន្ថែមបោះនៅក្នុងទឹកដីកម្ពុជា(ភ្លោះ ត្រី មានលេខរៀងដូចគ្នា) មានសរសេរឆ្នាំបោះបង្គោលនៅលើមុខបង្គោល។ ដោយឡែកបង្គោលព្រំដែនបំពេញបន្ថែមទោលមានលេខរៀងគូ និងបង្គោលព្រំដែនបំពេញបន្ថែមបោះនៅក្នុងទឹកដីវៀតណាម(ភ្លោះ ត្រី មានលេខរៀងដូចគ្នា) ពុំមានសរសេរឆ្នាំបោះបង្គោលនៅលើមុខបង្គោលទេ។



Media from www.moj.gov.kh resource from www.ocm.gov.kh

៣.៣-បង្គោលតម្រុយព្រំដែន៖ ធ្វើពីបេតុងសរសៃដែក ហើយមានទំហំតូចជាងបង្គោលព្រំដែនបំពេញបន្ថែម និងបោះនៅលើខ្សែព្រំដែន។ ដោយឡែកបង្គោលតម្រុយព្រំដែនមានលេខរៀងសេស មានសសេរបន្ថែមផ្ទាំបោះបង្គោលនៅលើមុខបង្គោល។ បង្គោលតម្រុយព្រំដែនមានលេខរៀងគូពុំមានសសេរបន្ថែមផ្ទាំបោះបង្គោលនៅលើមុខបង្គោលទេ ។

**៤-បទដ្ឋានក្នុងការបោះបង្គោលព្រំដែន៖**

**៤.១**-បង្គោលព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែមត្រូវបានបោះនៅត្រង់ទីតាំងដូចខាងក្រោម៖

៤.១.១- កន្លែងដែលខ្សែព្រំដែនផ្លាស់ប្តូរទិសដើរច្បាស់លាស់ (ចំណុចបត់)

៤.១.២-កន្លែងដែលខ្សែព្រំដែនពិបាកចំណាំនៅលើដី

៤.១.៣-កន្លែងប្រសព្វគ្នារវាងផ្លូវគោក ផ្លូវទឹកជាមួយខ្សែព្រំដែន

៤.១.៤-កន្លែងនៅជិតព្រំដែនមានប្រជាជនតាំងទីលំនៅច្រើន

៤.១.៥-ចំណុចប្រសព្វ ឬបំបែករបស់ផ្លូវទឹកខាងក្នុងជាមួយផ្លូវទឹកនៅតាមព្រំដែនកន្លែងផ្លូវទឹកបែកជាបី

៤.១.៦-កន្លែងដែលផ្លូវទឹកនៅតាមព្រំដែនងាយនឹងប្រែប្រួលចរន្តទឹកហូរ

៤.១.៧-កន្លែងដែលខ្សែព្រំដែនផ្លាស់ប្តូរពីដីគោកចុះទៅព្រំដែនផ្លូវទឹក ឬបញ្ច្រាស់វិញ

៤.១.៨-ចំណុចចាប់ផ្តើម និងចំណុចចុងក្រោយនៃការកំណត់ព្រំដែនត្រង់

៤.១.៩-ចំណុចខ្ពស់ដែលចាំបាច់។

**៤.២**-បង្គោលតម្រុយព្រំដែនត្រូវបានបោះនៅលើខ្សែព្រំដែននៅតំបន់ដែលខ្សែព្រំដែនត្រូវបានកែសម្រួលតាមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩ និងតំបន់ចាំបាច់មួយចំនួនសម្រាប់បង្ហាញខ្សែព្រំដែនឲ្យច្បាស់នៅលើដីជាក់ស្តែង។

**៥**-ទ្រង់ទ្រាយ និងទម្រង់បង្គោលព្រំដែនត្រូវបានបង្ហាញក្នុងសៀវភៅផែនទីព្រំដែនអមពិធីសារនេះ។

**៦**-ទីតាំងនៃបង្គោលនីមួយៗត្រូវបានពិពណ៌នាលម្អិត ក្នុងផ្នែកទី២ នៃពិធីសារនេះ។ ទន្ទឹមនឹងនេះ មានបង្ហាញនៅលើផែនទីព្រំដែនដែរ។ និយាមកាចតុរង្គ និយាមកាភូមិសាស្ត្រ និងបណ្តាព័ត៌មានផ្សេងទៀត នៃបង្គោលព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែមដែលបានបង្ហាញសុទ្ធតែបានសរសេរ

លម្អិតក្នុងតារាងចុះលេខបង្គោលព្រំដែន ឧបសម្ព័ន្ធ២ និងតារាងលទ្ធផលនិយាមកា និងរយៈកម្ពស់បង្គោលព្រំដែនឧបសម្ព័ន្ធ៣ អមពិធីសារនេះ។

**៧**-ភាគីទាំងពីរបោះបង្គោលព្រំដែនបានចំនួន ១ ៥៥៣ ទីតាំង ស្មើនឹង ២ ០៤៧ បង្គោល នៅលើដីជាក់ស្តែង ក្នុងនោះរួមមានដូចខាងក្រោម៖

៧.១-បង្គោលព្រំដែន៖

-បង្គោលព្រំដែនទោលមានចំនួន ២២៣ ទីតាំង ស្មើនឹង ២២៣ បង្គោល។

-បង្គោលព្រំដែនភ្លោះមានលេខរៀងដូចគ្នាមានចំនួន ៣១ ទីតាំង ស្មើនឹង ៦២ បង្គោល។

-បង្គោលព្រំដែនត្រីមានលេខរៀងដូចគ្នាមានចំនួន ១០ ទីតាំង ស្មើនឹង ៣០ បង្គោល។

៧.២-បង្គោលព្រំដែនបំពេញបន្ថែម៖

-បង្គោលទោលមានចំនួន ៦៧៤ ទីតាំង ស្មើនឹង ៦៧៤ បង្គោល។

-បង្គោលភ្លោះមានលេខរៀងដូចគ្នាមានចំនួន ៣៤៥ ទីតាំង ស្មើនឹង ៦៩០ បង្គោល។

-បង្គោលត្រីមានលេខរៀងដូចគ្នាមានចំនួន ៤៩ ទីតាំង ស្មើនឹង ១៤៧ បង្គោល។

៧.៣-បង្គោលតម្រុយព្រំដែន៖ មានចំនួន ២២១ បង្គោល។

៨-ភាគីកម្ពុជាសាងសង់បង្គោលព្រំដែនបំពេញបន្ថែមទោល បង្គោលតម្រុយព្រំដែនមានលេខរៀងសេស បង្គោលព្រំដែនបំពេញបន្ថែមភ្លោះមានលេខរៀងដូចគ្នា និងបង្គោលព្រំដែនបំពេញបន្ថែមត្រីមានលេខរៀងដូចគ្នាដែលស្ថិតក្នុងទឹកដីកម្ពុជា។ ភាគីវៀតណាមសាងសង់បង្គោលព្រំដែន បង្គោលព្រំដែនបំពេញបន្ថែមទោល បង្គោលតម្រុយព្រំដែនមានលេខរៀងគូ បង្គោលព្រំដែនបំពេញបន្ថែមភ្លោះមានលេខរៀងដូចគ្នា និងបង្គោលព្រំដែនបំពេញបន្ថែមត្រីមានលេខរៀងដូចគ្នា ដែលស្ថិតក្នុងទឹកដីវៀតណាម ។

**ប្រការ ៤ ៖ ចំណុចពិសេស**

ដើម្បីធ្វើឱ្យច្បាស់ទិសដើរនៃខ្សែព្រំដែននៅលើដីជាក់ស្តែង ភាគីទាំងពីរបានកំណត់ចំណុចពិសេសបានចំនួន [១០៩១] ចំណុច ដែលមាននិយាមកាភូមិសាស្ត្រវាស់នៅលើដីជាក់ស្តែង ដោយម៉ាស៊ីន GPS ២ប្រេកង់ ឬវាស់ដោយម៉ាស៊ីន Total Station។ និយាមកាភូមិសាស្ត្រនៃចំណុចពិសេសនីមួយៗ មានពិពណ៌នាលម្អិតនៅផ្នែកទី២ នៃពិធីសារនេះ។

**ប្រការ ៥ ៖ និយាមការ រយៈកម្ពស់ និងចម្ងាយ ដែលពាក់ព័ន្ធដល់បង្គោលព្រំដែន**

១-និយាមកាភូមិសាស្ត្រប្រើប្រាស់ ដើម្បីពិពណ៌នាទិសដើរ នៃខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែន បង្គោលតម្រុយព្រំដែនក្នុងពិធីសារនេះ ត្រូវបានកំណត់តាមប្រព័ន្ធនិយាមកាសកលឆ្នាំ១៩៨៤ (WGS-84) និងខ្នាតរយៈកម្ពស់ប្រើប្រាស់ទម្រង់ប្រជុំកម្លាំងសកល ២០០៨ (EGM2008) ដើម្បីគណនា។

២-និយាមកាចតុរង្គប្លង់រាបនៃបង្គោលព្រំដែន និងចំណុចពិសេសត្រូវបានគណនាប្តូរពីនិយាមកាភូមិសាស្ត្ររបស់បង្គោលព្រំដែននៃចំណុចពិសេសនោះតាមចំណោល UTM(WGS-84)ចំណោល ៦° ខ្សែអ័ក្ស១០៥° [រយៈបណ្តោយខាងកើត។]

៣-រយៈកម្ពស់បង្គោលព្រំដែន ឬបង្គោលតម្រុយ ជារយៈកម្ពស់ផ្ទៃដីធម្មជាតិ ឬផ្ទៃដីសិប្បនិម្មិត នៅទីតាំងបង្គោលព្រំដែន ឬបង្គោលតម្រុយនោះ ហើយត្រូវបានគណនាដោយយករយៈកម្ពស់កំពូលបង្គោល បង្គោលតម្រុយព្រំដែន ដកកម្ពស់បង្គោល បង្គោលតម្រុយព្រំដែននោះ។

៤-ទិន្នន័យនិយាមកាភូមិសាស្ត្រ នៃបង្គោលព្រំដែន បង្គោលតម្រុយ និងមុំអាស៊ីមូត រវាងបង្គោលព្រំដែនបន្តបន្ទាប់មានបង្គោលភ្លោះមានលេខរៀងដូចគ្នា បង្គោលត្រីមានលេខរៀងដូចគ្នាប្រើប្រាស់ក្នុងការពិពណ៌នាតាមខ្នាត (ដឺក្រេ នាទី វិនាទី) កម្រិតជាក់លាក់នៅក្រោយខ្នាតយកដល់ ០៣ ខ្ទង់ (0.00១") ហើយទិន្នន័យនិយាមកា និងរយៈកម្ពស់ចតុរង្គប្លង់រាប និងប្រវែងប្រើប្រាស់ខ្នាតគិតជាម៉ែត្រ (ម) ដោយយកកម្រិតជាក់លាក់នៅក្រោយខ្នាតយកដល់ ០២ខ្ទង់ (0.0១ម)។

៥-ចម្ងាយរវាងបង្គោលព្រំដែនភ្លោះនិងបង្គោលព្រំដែនត្រី និងចម្ងាយពីបង្គោលព្រំដែនភ្លោះ បង្គោលព្រំដែនត្រីនីមួយៗទៅខ្សែព្រំដែន និងពីបង្គោលព្រំដែនត្រីដល់ចំណុចប្រសព្វ ឬចំណុចបំបែកផ្លូវទឹកព្រំដែន និងផ្លូវទឹកផ្នែកខាងក្នុងទឹកដី នៃប្រទេសទាំងពីរត្រូវវាស់លើដីជាក់ស្តែងយកដល់ 0.0១ម។

៦-ការវាស់វែងនិយាមកា និងរយៈកម្ពស់ នៃបង្គោលតម្រុយព្រំដែន និងចំណុចពិសេសលើដីជាក់ស្តែងត្រូវបានអនុវត្តដូចការវាស់វែងបង្គោលព្រំដែន។

**ប្រការ ៦ ៖ ព្រំដែនផ្លូវទឹក និងដីកោះ នៅតាមព្រំដែនផ្លូវទឹក**

១-ព្រំដែនផ្លូវទឹកដែលពិពណ៌នាក្នុងពិធីសារនេះ ត្រូវបានបែងចែកជាព្រំដែនផ្លូវទឹកដែលអាចធ្វើនាវាចរបាន និងព្រំដែនផ្លូវទឹកដែលមិនអាចធ្វើនាវាចរបាន។

ក-ចំពោះព្រំដែនផ្លូវទឹកអាចធ្វើនាវាចរបាន គឺខ្សែព្រំដែនដើរតាមខ្សែទ្រូងជ្រលងទឹក ឬខ្សែទ្រូងជ្រលងទឹកជ្រៅ។

ខ-ចំពោះព្រំដែនផ្លូវទឹកដែលពុំអាចធ្វើនាវាចរបាន គឺខ្សែព្រំដែនដើរតាមខ្សែទ្រូងចរន្តទឹកហូរ ឬខ្សែទ្រូងចរន្តទឹកមេ។

២-ភាគីទាំងពីរឯកភាពលទ្ធផលនៃការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនលើដីជាក់ស្តែង ដើម្បីកំណត់ការបែងចែកកម្មសិទ្ធិដីកោះ នៅតាមព្រំដែនផ្លូវទឹក។ លេខរៀង និងការបែងចែកកម្មសិទ្ធិកោះ ដីដុះ នៅតាមព្រំដែនផ្លូវទឹក ត្រូវបានដាក់តាមព្រំដែនផ្លូវទឹកនីមួយៗបន្តបន្ទាប់គ្នាតាមទិសដើរ នៃខ្សែព្រំដែន និងត្រូវបានកត់ត្រាក្នុង "តារាងរាយនាមកម្មសិទ្ធិដីកោះនៅតាមព្រំដែនផ្លូវទឹក" ឧបសម្ព័ន្ធ៤ អមពិធីសារ និងជាផ្នែកមួយ នៃគ្រោងពិធីសារ។

ប្រសិនបើមានដីកោះ ដែលទើបកើតមានឡើងថ្មីៗនៅតាមព្រំដែនផ្លូវទឹក គឺត្រូវយោងតាមខ្សែព្រំដែនដែលបានខណ្ឌសីមារួច ដើម្បីធ្វើការបែងចែកកម្មសិទ្ធិ។ ប្រសិនបើដីកោះ ដែលទើបកើតមានឡើងស្ថិតនៅលើខ្សែព្រំដែនដែលបានខណ្ឌសីមារួច ភាគីទាំងពីរនឹងពិភាក្សា និងកំណត់ការបែងចែកកម្មសិទ្ធិ ដោយឈរលើមូលដ្ឋានស្មើភាព សមហេតុផល ។

៣-ក្នុងករណីផ្លូវទឹកតាមព្រំដែនប្តូរចរន្ត គឺខ្សែព្រំដែននៅក្បាលដែលមិនមានការប្រែប្រួលឡើយ។

**ប្រការ ៧ ៖ ផែនទីឋានលេខាព្រំដែនកម្ពុជា-វៀតណាម**

១-ផែនទីឋានលេខាព្រំដែនកម្ពុជា-វៀតណាម មាត្រដ្ឋាន ១/២៥ ០០០ ផលិតដោយក្រុមហ៊ុន Niras Mapping A/S (មុននេះហៅថាក្រុមហ៊ុន Blom Info A/S នៅឆ្នាំ២០១១ ក្រោយមកប្តូរឈ្មោះទៅជាក្រុមហ៊ុន Niras Mapping A/S នៅឆ្នាំ២០១៣) រួមមាន ៩២ (កៅសិបពីរ) ផ្ទាំង ត្រូវបានដាក់លេខរៀងពីទិសខាងជើងចុះមកទិសខាងត្បូង ពីទិសខាងលិចមកទិសខាងកើត ដោយចាប់ពីផ្ទាំងផែនទីលេខ១ ដល់លេខ៩២ និងត្រូវបានធ្វើជាពីរសំណុំ ដែលមួយសំណុំជាភាសាខ្មែរ-វៀតណាម និងមួយសំណុំទៀត ជាភាសាវៀតណាម-ខ្មែរ ក្នុងនោះ ៖

១.១-ផែនទីចំនួន ០៨ ផ្ទាំង ដែលមានលេខ២៨ ៣៣ ៣៦ ៥០ ៥៩ ៦២ ៧៩ ៨២ ពុំមានបង្ហាញខ្សែព្រំដែនទេ ដោយគ្រាន់តែបង្ហាញដែនដីនៃភាគីម្ខាងៗតែប៉ុណ្ណោះ។

១.២-ផែនទីចំនួន ០៦ ផ្ទាំង ដែលមានលេខ១៥ ១៦ ១៧ ១៨ ១៩ ២០ ពុំទាន់បង្ហាញខ្សែព្រំដែនទេ និង២៥ផ្ទាំងផែនទី ដែលមានលេខ១១ ១៣ ១៤ ២១ ៣០ ៣១ ៣៧ ៤៥ ៤៦ ៥៧ ៥៨ ៦៣ ៦៤ ៦៥ ៦៦ ៦៧ ៦៨ ៦៩ ៧០ ៧២ ៧៣ ៨១ ៨៣ ៨៩ ៩០ ពុំទាន់បង្ហាញខ្សែព្រំដែនឱ្យបានពេញលេញ ដោយសារពុំទាន់មានលទ្ធផលខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរ។

២-ផែនទីឋានលេខាព្រំដែនខ្នាត ១/២៥ ០០០ ជាធាតុផ្សំមួយដែលមិនអាចផ្តាច់ចេញបានពីពិធីសារនេះ ដោយប្រើប្រាស់ប្រព័ន្ធនិយាមកាសកល WGS-84 ចំណោល UTM ចំណោល៦° ខ្សែអ័ក្ស ១០៥° រយៈបណ្តោយខាងកើត ខ្នាតរយៈកម្ពស់ (EGM2008)។

ទំហំគូរ និងវាស់ផែនទីគិតពីខ្សែព្រំដែនទៅភាគីម្ខាងៗមានប្រវែង ៥គីឡូម៉ែត្រ (ប្រាំគីឡូម៉ែត្រ)។

៣-ក្នុងករណីជាក់ស្តែងមួយចំនួនដែលខ្សែព្រំដែនជាបន្ទាត់ត្រង់ ត្រូវបានបង្ហាញនៅលើផែនទី ដូចខាងក្រោម៖

៣.១-នៅពេលខ្សែព្រំដែនត្រួតស៊ីជាមួយផ្លូវទឹក សញ្ញាសម្គាល់ជាបន្ទាត់មានគំនូស១ ឬផ្លូវទឹកមាន២គំនូស មានទំហំតូចជាង ឬស្មើ០.៦មីលីម៉ែត្រ នៅលើផែនទី ដូចនេះ ខ្សែព្រំដែនត្រូវបានបង្ហាញដោយការគូសឆ្លាស់គ្នានៅសងខាងសញ្ញាសម្គាល់នោះ។ ប្រវែងគំនូសឆ្លាស់គ្នានេះ មានពី២-៣ សង់ទីម៉ែត្រ នៅលើផែនទី។

៣.២-នៅពេលខ្សែព្រំដែនដើរតាមខ្សែទ្រូងចរន្តទឹកហូរ ឬខ្សែទ្រូងចរន្តទឹកហូរមេ នៃព្រំដែនផ្លូវទឹកដែលមានទំហំធំជាង ០.៦ មីលីម៉ែត្រ នៅលើផែនទី ឬខ្សែទ្រូងជ្រលងទឹក ឬខ្សែទ្រូងជ្រលងទឹកជ្រៅតាមព្រំដែនផ្លូវទឹកដែលអាចធ្វើនាវាចរបាន ដូចនេះ ខ្សែព្រំដែនត្រូវបានបង្ហាញត្រួតស៊ីជាមួយខ្សែទ្រូងចរន្តទឹកហូរ ឬខ្សែទ្រូងចរន្តទឹកហូរមេ ខ្សែទ្រូងជ្រលងទឹក ឬខ្សែទ្រូងជ្រលងទឹកជ្រៅ នៃព្រំដែនផ្លូវទឹកនោះ ។

៣.៣-ដើម្បីបង្ហាញឱ្យច្បាស់ និងជាក់លាក់នូវទីតាំងបង្គោលព្រំដែន នូវកំណាត់ព្រំដែនដែលមានទីតាំងបង្គោលព្រំដែនញឹកពេក ភាគីទាំងពីរឯកភាពធ្វើប្លង់ពង្រីក ដោយដាក់នៅទីតាំងសមស្របក្នុងផ្ទាំងផែនទីនីមួយៗ ដើម្បីបង្ហាញទីតាំងបង្គោលព្រំដែន និងកំណាត់ព្រំដែនដែលពាក់ព័ន្ធ។

**ប្រការ ៨ ៖ គោលការណ៍ពិពណ៌នាខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែន**

ការពិពណ៌នាទិសដើរនៃខ្សែព្រំដែនត្រូវបានអនុវត្តតាមបទកំណត់ដូចខាងក្រោម៖

១-ការពិពណ៌នាទិសដើរនៃខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែនត្រូវតែមានភាពជាក់លាក់ ពេញលេញ និងច្បាស់លាស់ ត្រឹមត្រូវតាមលទ្ធផលខណ្ឌសីមា និងបោះបង្គោលព្រំដែនដែលភាគីបានឯកភាពគ្នា បង្ហាញលើផែនទីឋានលេខាព្រំដែនខ្នាត ១/២៥ ០០០។

២-ទិសដើរនៃខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែន ត្រូវបានពិពណ៌នាជាប់គ្នាបន្តបន្ទាប់តាមទិស និងលេខរៀងពីជើងចុះទៅត្បូង ពីបង្គោលព្រំដែនទៅបង្គោលព្រំដែនបន្តបន្ទាប់តាមកំណាត់ព្រំដែននីមួយៗតភ្ជាប់រវាងពីរបង្គោលព្រំដែនបន្តបន្ទាប់ (មិនចាំបាច់គិតថា ជាបង្គោលព្រំដែន ឬបង្គោលព្រំដែនបំពេញបន្ថែម) ហើយក្នុងករណីកំណាត់ព្រំដែនមិនដើរតាមខ្សែត្រង់ គឺទិសដើរនៃខ្សែព្រំដែនត្រូវបានពិពណ៌នាតាម "ទិសរួម" ហើយក្នុងករណីកំណាត់ព្រំដែនដើរតាមខ្សែត្រង់ ទិសដើរនៃខ្សែព្រំដែនត្រូវបានពិពណ៌នាដោយផ្ទាល់ តាមទិសកំណាត់ព្រំដែន។ ក្នុងកំណាត់ព្រំដែននីមួយៗ នៅពេលពិពណ៌នាអំពីការប្រែប្រួលលក្ខណៈពិសេសភូមិសាស្ត្រ ដែលខ្សែព្រំដែនដើរកាត់ ឬមានការប្តូរទិសច្បាស់លាស់នៃខ្សែព្រំដែន គឺប្រើប្រាស់ពាក្យឆ្លាស់គ្នា "ក្រោយនោះ" និង "រួចហើយ"។

៣-នៅពេលពិពណ៌នាខ្សែព្រំដែន ចាំបាច់ត្រូវពិពណ៌នាបង្គោលព្រំដែន។ ព័ត៌មានអំពីបង្គោលព្រំដែន និងបង្គោលព្រំដែនបំពេញបន្ថែមត្រូវបានពិពណ៌នាលម្អិតពេញលេញ និងជាក់លាក់អំពី



Media from www.moj.gov.kh resource from www.ocm.gov.kh

ទ្រង់ទ្រាយ និងវត្ថុជាតុបង្គោល និងទីតាំងភូមិសាស្ត្រ (កំពូលភ្នំ ខ្នងភ្នំ ចង្កេះភ្នំ និងច្រាំងទន្លេ ជ្រោះ..) និយាមកាភូមិសាស្ត្រ និងរយៈកម្ពស់នៃបង្គោលនោះត្រូវបានវាស់នៅលើដីជាក់ស្តែងដោយម៉ាស៊ីន GPS 2 ហ្វ្រេកង់។ បង្គោលតម្រុយព្រំដែនគ្រាន់តែពិពណ៌នា និយាមកាភូមិសាស្ត្រ និងរយៈកម្ពស់ ចំពោះចំណុចពិសេសគ្រាន់តែពិពណ៌នានិយាមកាភូមិសាស្ត្រ។

៤-និយាមកា និងរយៈកម្ពស់ទីតាំងបង្គោលព្រំដែន ត្រូវបានវាស់នៅលើដីជាក់ស្តែង រាល់កត្តាភូមិសាស្ត្រ វត្ថុជាតុគោល នាមតំបន់ និងបណ្តាចំណុចពិសេសដែលពាក់ព័ន្ធដោយផ្ទាល់ដល់ខ្សែព្រំដែន ឬបង្គោលព្រំដែន ដូចជា (ចំណុចរយៈកម្ពស់ កំពូលភ្នំ ខ្នងភ្នំ ចង្កេះភ្នំ ជម្រាលភ្នំ ចំណុចប្តូរទិសនៃខ្សែព្រំដែន និងទីកន្លែងដែលខ្សែព្រំដែនប្តូរពីភូមិសាស្ត្រនេះទៅភូមិសាស្ត្រផ្សេងទៀត) សុទ្ធតែត្រូវបានបង្ហាញក្នុងការពិពណ៌នា។

៥-នាមតំបន់ដែលឯកភាពយកមកប្រើក្នុងការពិពណ៌នា ជានាមតំបន់នៅលើផែនទីឋានលេខាព្រំដែនខ្នាត១/២៥ ០០០។ ចំពោះបណ្តានាមតំបន់នៃភាគីនីមួយៗដែលមានការហៅឈ្មោះផ្សេងគ្នា ក្នុងឯកសារពិពណ៌នាជាភាសាវៀតណាម ឈ្មោះតំបន់ជាភាសាវៀតណាមសរសេរនៅខាងមុខ ហើយឈ្មោះតំបន់ជាភាសាខ្មែរសរសេរនៅខាងក្រោយ ដាក់ក្នុងសញ្ញាវង់ក្រចក ( ) និងបញ្ជាស់មកវិញ។

៦-ខ្សែព្រំដែនដើរតាមខ្នងភ្នំ ដោយកាត់តាមបណ្តាកំពូលភ្នំ ឬកាត់តាមបណ្តាចំណុចខ្ពស់ត្រូវតែពិពណ៌នាលម្អិតបន្តបន្ទាប់កាត់តាមកំពូលភ្នំ ខ្នងភ្នំ ជម្រាលភ្នំ និងចំណុចខ្ពស់។

៧-ខ្សែព្រំដែនដើរតាមផ្លូវទឹកត្រូវពិពណ៌នាឱ្យមានភាពជាក់ស្តែង និងជាក់លាក់ទិស នៃខ្សែព្រំដែនស្រប ឬ បញ្ច្រាស់តាមខ្សែទ្រូងចរន្តទឹកហូរ ឬខ្សែទ្រូងចរន្តទឹកមេ ខ្សែទ្រូងជ្រលងទឹក ឬខ្សែទ្រូងជ្រលងទឹកជ្រៅ នៃផ្លូវទឹកនោះ។

៨-ក្នុងករណីកំណាត់ព្រំដែនដើរតាមខ្សែត្រង់ ត្រូវពិពណ៌នានិយាមកាភូមិសាស្ត្រ (វាស់នៅលើដីជាក់ស្តែង) នៃចំណុចចាប់ផ្តើម និងចំណុចចុងក្រោយ នៃកណាត់ព្រំដែននោះ ។

៩-ចម្ងាយរវាងពីចំណុចណាមួយដែលបានលើកឡើងក្នុងពិធីសារ ជាចម្ងាយក្នុងប្លង់រាប។ ពេលដែលខ្សែព្រំដែនរវាងពីរបង្គោលបន្តបន្ទាប់គ្នាជាខ្សែត្រង់ ដូចនេះ ចម្ងាយរបស់ខ្សែព្រំដែនត្រូវបានគណនាតាមនិយាមកាចតុរង្គប្លង់រាបនៃបង្គោលព្រំដែនបន្តបន្ទាប់ ហើយប្រវែងនៃកំណាត់ព្រំដែនរវាងពីរបង្គោលព្រំដែនបន្តបន្ទាប់ត្រូវបានវាស់នៅលើផែនទីព្រំដែន ដោយយកដល់ ០.០០១ គីឡូម៉ែត្រ។

១០-ទំនាក់ទំនងរវាងទិសដើរនៃខ្សែព្រំដែន និងភូមិសាស្ត្រដែលខ្សែព្រំដែនដើរកាត់ត្រូវបានពិពណ៌នាតាមទិស និងមុំអាស៊ីមូតតាមបទកំណត់ខាងក្រោម៖

| | |
|---|---|
| ជើង | 348°45' ដល់ 11°15' |
| ជើងឆៀងឦសាន | 11°15' ដល់ 33°45' |
| ឦសាន | 33°45' ដល់ 56°15' |



Media from www.moj.gov.kh resource from www.ocm.gov.kh

| | |
|---|---|
| កើតទៀងឦសាន | $56^{0}15'$ ដល់ $78^{0}45'$ |
| កើត | $78^{0}45'$ ដល់ $101^{0}15'$ |
| កើតទៀងអាគ្នេយ៍ | $101^{0}15'$ ដល់ $123^{0}45'$ |
| អាគ្នេយ៍ | $123^{0}45'$ ដល់ $146^{0}15'$ |
| ត្បូងទៀងអាគ្នេយ៍ | $146^{0}15'$ ដល់ $168^{0}45'$ |
| ត្បូង | $168^{0}45'$ ដល់ $191^{0}15'$ |
| ត្បូងទៀងនិរតី | $191^{0}15'$ ដល់ $213^{0}45'$ |
| និរតី | $213^{0}45'$ ដល់ $236^{0}15'$ |
| លិចទៀងនិរតី | $236^{0}15'$ ដល់ $258^{0}45'$ |
| លិច | $258^{0}45'$ ដល់ $281^{0}15'$ |
| លិចទៀងពាយ័ព្យ | $281^{0}15'$ ដល់ $303^{0}45'$ |
| ពាយ័ព្យ | $303^{0}45'$ ដល់ $326^{0}15'$ |
| ជើងទៀងពាយ័ព្យ | $326^{0}15'$ ដល់ $348^{0}45'$ |



Media from www.moj.gov.kh resource from www.ocm.gov.kh

## ផ្នែកទី ២

## ទិសដើរនៃខ្សែព្រំដែន ទីតាំងបង្គោលព្រំដែន

### ប្រការ ៩ ៖ ពិពណ៌នាលម្អិតអំពីខ្សែព្រំដែន និងបង្គោលព្រំដែន

ចំណុចចាប់ផ្តើមខ្សែព្រំដែនគោក កម្ពុជា-វៀតណាម ជាចំណុចប្រសព្វនៃខ្សែព្រំដែនទាំងបីប្រទេស កម្ពុជា-វៀតណាម-ឡាវ។

បង្គោលព្រំដែននៅចំណុចប្រសព្វខ្សែព្រំដែនទាំងបីប្រទេស កម្ពុជា-វៀតណាម-ឡាវ ជាបង្គោលព្រំដែនទោល ដោយប្លង់បង្គោលមានលក្ខណៈពិសេសមានមុខបី ហើយនៅលើមុខទាំងបីមានភ្ជាប់សញ្ញាជាតិទាំងបីប្រទេស បោះនៅលើកំពូលភ្នំត្រង់ចំណុចមានិយាមកាភូមិសាស្ត្រ 14°41'09.800" រយៈទទឹងខាងជើង 107°33'23.790" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 1081.00 ម៉ែត្រ ។

ពីបង្គោលព្រំដែនដែលជាចំណុចប្រសព្វនៃខ្សែព្រំដែនទាំងបីប្រទេស ខ្សែព្រំដែនដើរតាមទិសរួម ទៅទិសនិរតី តាមខ្នងភ្នំ រួចកាត់ចំណុចមានរយៈកម្ពស់ 896.60 ម៉ែត្រ (នៅលើផែនទី) ដល់បង្គោលលេខ 0/1 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 1.188 គីឡូម៉ែត្រ ។

បង្គោលលេខ 0/1 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើកំពូលភ្នំ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 14°40'45.607" រយៈទទឹងខាងជើង 107°32'59.819" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 897.12 ម៉ែត្រ ។

ពីបង្គោលលេខ 0/1 ខ្សែព្រំដែនដើរតាមទិសរួម ទៅទិសខាងត្បូង តាមខ្នងភ្នំ កាត់តាមកំពូលភ្នំមានរយៈកម្ពស់ 892.60 ម៉ែត្រ(នៅលើផែនទី)ដល់បង្គោលលេខ 0/2 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.792 គីឡូម៉ែត្រ ។

បង្គោលលេខ 0/2 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើកំពូលភ្នំ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 14°40'23.137" រយៈទទឹងខាងជើង 107°32'59.477" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 916.43 ម៉ែត្រ។

ពីបង្គោលលេខ 0/2 ខ្សែព្រំដែនដើរតាមទិសរួម ទៅទិសអាគ្នេយ៍ តាមខ្នងភ្នំ កាត់តាមកំពូលភ្នំមានរយៈកម្ពស់ 911.70 ម៉ែត្រ(នៅលើផែនទី) ដល់បង្គោលលេខ 0/3 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.857 គីឡូម៉ែត្រ ។

បង្គោលលេខ 0/3 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើកំពូលភ្នំ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 14°40'03.462" រយៈទទឹងខាងជើង 107°33'16.306" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 920.38 ម៉ែត្រ។

ពីបង្គោលលេខ 0/3 ខ្សែព្រំដែនដើរតាមទិសរួម ទៅទិសខាងត្បូង តាមខ្នងភ្នំ រួចចុះកាត់ជ្រលងភ្នំមានរយៈកម្ពស់ 822.10 ម៉ែត្រ(នៅលើផែនទី) ក្រោយមកប្តូរទិស ទៅទិសខាងត្បូងឆៀងនិរតី ឡើងតាមខ្នងភ្នំ រួចកាត់តាមកំពូលភ្នំបន្តបន្ទាប់មានរយៈកម្ពស់ 905.40 ម៉ែត្រ និង 901.20 ម៉ែត្រ(នៅលើផែនទី) រួចកាត់ផ្លូវដី ដល់បង្គោលលេខ 0/4 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 1.219 គីឡូម៉ែត្រ ។



Media from www.moj.gov.kh resource from www.ocm.gov.kh

ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'33.591" រយៈទទឹងខាងជើង 104°27'06.957" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 1.93 ម៉ែត្រ ។

ពីបង្គោលលេខ 313/1 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/2។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.167 គីឡូម៉ែត្រ។

បង្គោលលេខ 313/2 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើដីលិចទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'32.415" រយៈទទឹងខាងជើង 104°27'01.580" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 1.93 ម៉ែត្រ។

ពីបង្គោលលេខ 313/2 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/3 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.209 គីឡូម៉ែត្រ។

បង្គោលលេខ 313/3 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើដីលិចទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'30.950" រយៈទទឹងខាងជើង 104°26'54.879" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 2.07 ម៉ែត្រ។

ពីបង្គោលលេខ 313/3 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/4 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.200 គីឡូម៉ែត្រ។

បង្គោលលេខ 313/4 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើភ្លឺស្រែ ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'29.548" រយៈទទឹងខាងជើង 104°26'48.468" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 2.40 ម៉ែត្រ។

ពីបង្គោលលេខ 313/4 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/5 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.136 គីឡូម៉ែត្រ។

បង្គោលលេខ 313/5 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើដីលិចទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'28.598" រយៈទទឹងខាងជើង 104°26'44.099" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 1.81 ម៉ែត្រ។

ពីបង្គោលលេខ 313/5 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/6 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.184 គីឡូម៉ែត្រ។

បង្គោលលេខ 313/6 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើដីលិចទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'27.300" រយៈទទឹងខាងជើង 104°26'38.183" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 1.86 ម៉ែត្រ។

ពីបង្គោលលេខ 313/6 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលលេខ 313/7 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.176 គីឡូម៉ែត្រ។

បង្គោលលេខ 313/7 ជាបង្គោលព្រំដែនបំពេញបន្ថែមទោល បោះនៅលើដីលិចទឹក ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'26.067" រយៈទទឹងខាងជើង 104°26'32.524" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 2.03 ម៉ែត្រ។



Media from www.moj.gov.kh resource from www.ocm.gov.kh

ពីបង្គោលលេខ 313/7 ខ្សែព្រំដែនដើរទៅទិសខាងលិចឆៀងនិរតី តាមខ្សែត្រង់ ដល់បង្គោលព្រំដែនលេខ 314 ។ កំណាត់ខ្សែព្រំដែននេះមានប្រវែង 0.186 គីឡូម៉ែត្រ។

បង្គោលព្រំដែនលេខ 314 ជាបង្គោលទោល ប្រភេទពិសេស បោះនៅចំណុចចុងបញ្ចប់នៃខ្សែព្រំដែនដីគោក កម្ពុជា-វៀតណាម ត្រង់ចំណុចមាននិយាមកាភូមិសាស្ត្រ 10°25'24.764" រយៈទទឹងខាងជើង 104°26'26.549" រយៈបណ្តោយខាងកើត និងមានរយៈកម្ពស់ 4.54 ម៉ែត្រ។

**ប្រការ ១០ ៖ សុពលភាព នៃផែនទី**

ក្នុងកម្រិតខ្សែព្រំដែនដែលបានធ្វើបញ្ចប់ខណ្ឌសីមា និងបោះបង្គោលព្រំដែន ត្រូវបានកត់ត្រាលម្អិតត្រង់ប្រការ ៩ នៃពិធីសារនេះ សមស្របតាមចំណុច៤ ប្រការ៤ នៃសន្ធិសញ្ញាឆ្នាំ២០០៥ ហើយរាល់ផ្ទាំងផែនទីឋានលេខាព្រំដែនមាត្រដ្ឋាន ១/២៥ ០០០ នៃឧបសម្ព័ន្ធ១ នៃពិធីសារនេះ នឹងជំនួសផ្ទាំងផែនទី ឬមួយផ្នែកខ្លះនៃផ្ទាំងផែនទី ដូចគ្នាជាមួយបណ្តាកំណាត់ព្រំដែនដែលបានខណ្ឌសីមា និងបោះបង្គោលព្រំដែន ក្នុងផែនទី Bonne មាត្រដ្ឋាន ១/១០០ ០០០ ចំនួន២៦ផ្ទាំង និងផែនទី UTM មាត្រដ្ឋាន ១/៥០ ០០០ ទាំង៤០ ផ្ទាំង អមសន្ធិសញ្ញាឆ្នាំ១៩៨៥ និងជំនួសរាល់ផ្នែកដូចគ្នាក្នុងប្លង់ទាំង០៤ អមសន្ធិសញ្ញាឆ្នាំ២០០៥ និងជំនួស ៣១ ប្លង់ អមសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩។

**ប្រការ ១១ ៖ ស្តីពីកំណាត់ព្រំដែនដែលពុំទាន់ខណ្ឌសីមា និងបោះបង្គោលព្រំដែន**

១-យោងតាមសន្ធិសញ្ញាឆ្នាំ១៩៨៥ សន្ធិសញ្ញាឆ្នាំ២០០៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩ ភាគីទាំងពីរនឹងបន្តសហការធ្វើបញ្ចប់ទាំងស្រុងការងារខណ្ឌសីមា និងបោះបង្គោលព្រំដែន នៅកំណាត់ព្រំដែន ដែលពុំទាន់ពិពណ៌នា ត្រង់ប្រការ ៩ នៃពិធីសារនេះ និងពុំទាន់បានបង្ហាញលើផែនទីឋានលេខាព្រំដែនមាត្រដ្ឋាន ១/២៥ ០០០ ជាក់ស្តែងដូចខាងក្រោម៖

១.១-ចំពោះកំណាត់ព្រំដែន ដែលបានឯកភាពលើលទ្ធផលគូសចម្លងខ្សែព្រំដែនពីផែនទី Bonne មាត្រដ្ឋាន ១/១០០ ០០០ ទៅលើផែនទី UTM មាត្រដ្ឋាន ១/៥០ ០០០ ខ្សែព្រំដែននៅកំណាត់ព្រំដែនទាំងនេះ ត្រូវបានកំណត់តាមលទ្ធផលនៃការគូសចម្លង។

១.២-ចំពោះកំណាត់ព្រំដែនតាមផ្លូវទឹក ខ្សែព្រំដែនត្រូវបានកំណត់តាមបទកំណត់នៅត្រង់វាក្យខ័ណ្ឌ១ ប្រការ១ នៃសន្ធិសញ្ញាឆ្នាំ២០០៥។

១.៣-ចំពោះកំណាត់ព្រំដែនពីបង្គោលលេខ២៤១ ដល់ទីតាំងព្រាងបោះបង្គោលព្រំដែនលេខ២៤៥(តំបន់ចន្លោះទន្លេមេគង្គ-បាសាក់ ខេត្តកណ្តាល-អានយ៉ាង) ខ្សែព្រំដែនត្រូវបានកំណត់តាមបទកំណត់ត្រង់វាក្យខ័ណ្ឌ ១.៤ ប្រការ២ នៃសន្ធិសញ្ញាឆ្នាំ២០០៥។

១.៤-ចំពោះកំណាត់ព្រំដែនដែលពុំស្ថិតក្នុងករណីដូចចំណុច១.១ ១.២ និង១.៣ នៃវាក្យខ័ណ្ឌ១ នៃប្រការនេះ ខ្សែព្រំដែនត្រូវបានកំណត់តាមបទកំណត់ត្រង់វាក្យខ័ណ្ឌ១ ប្រការ៣ នៃសន្ធិសញ្ញាឆ្នាំ២០០៥ ។

២-បញ្ជីឈ្មោះកំណាត់ព្រំដែន ដែលពុំទាន់បានបញ្ចប់ការងារខណ្ឌសីមា និងបោះបង្គោលព្រំដែនមាននៅ ក្នុងឧបសម្ព័ន្ធ៥ អមពិធីសារនេះ ។

## ផ្នែកទី ៣
## ការគ្រប់គ្រង ការពារ ការត្រួតពិនិត្យខ្សែព្រំដែន និងបណ្ដាញបង្គោលព្រំដែន

### ប្រការ ១២ ៖ ស្ដីពីការគ្រប់គ្រង ការពារខ្សែព្រំដែន បង្គោលព្រំដែន

១-ក្រោយពីពិធីសារនេះចូលជាធរមាន ភាគីទាំងពីរនឹងយោងតាមខ្សែព្រំដែនដែលបានពិពណ៌នាត្រង់ប្រការ ៩ នៃពិធីសារ នឹងបង្ហាញនៅលើផែនទីឋានលេខាព្រំដែនខ្នាត ១/២៥ ០០០ អមដើម្បីដំណើរការគ្រប់គ្រង ត្រួតពិនិត្យ ការពារខ្សែព្រំដែន និងបង្គោលព្រំដែន។

២-ចំពោះកំណាត់ព្រំដែនដែលពុំទាន់បញ្ចប់ការខណ្ឌសីមា និងបោះបង្គោលព្រំដែន ការគ្រប់គ្រងខ្សែព្រំដែន នឹងត្រូវបានបន្តអនុវត្តតាមចំណុច៥ ប្រការ៣ នៃសន្ធិសញ្ញា២០០៥ ។

### ប្រការ ១៣ ៖ ស្ដីពីការត្រួតពិនិត្យខ្សែព្រំដែនចម្រុះ

១-ក្រោយពីពិធីសារនេះចូលជាធរមានរាល់ ១០(ដប់) ឆ្នាំម្ដង ឬក្នុងករណីចាំបាច់ រដ្ឋាភិបាលនៃប្រទេសទាំងពីរ នឹងបង្កើតក្រុមត្រួតពិនិត្យព្រំដែនចម្រុះ ដើម្បីដំណើរការត្រួតពិនិត្យព្រំដែនរួមគ្នា។ បែបបទនៃការបង្កើតក្រុមត្រួតពិនិត្យចម្រុះ ខ្លឹមសារ វិធីសាស្ត្រធ្វើការ និងបញ្ហាពាក់ព័ន្ធផ្សេងៗ ភាគីទាំងពីរនឹងព្រមព្រៀងគ្នាជាឯកសារ តាមរយៈឯកសារផ្លូវការទូត។

២-ក្នុងករណីមានការប្រែប្រួលភូមិសាស្ត្រនៅលើដីជាក់ស្ដែង ភាគីទាំងពីរនឹងធ្វើពិធីសាររួមដើម្បីកត់ត្រាលទ្ធផលត្រួតពិនិត្យ ក្នុងនោះពិពណ៌នាឡើងវិញ អំពីលក្ខណៈពិសេស នៃភូមិសាស្ត្រដែលខ្សែព្រំដែនដើរកាត់។ បន្ទាប់ពីថ្នាក់លើមានសិទ្ធិអំណាចនៃប្រទេសទាំងពីរអនុម័តហើយពិធីសារត្រួតពិនិត្យរួម នឹងក្លាយទៅជាឯកសារបំពេញបន្ថែម និងជាធាតុផ្សំមួយពុំអាចផ្ដាច់ចេញនៃពិធីសារនេះ។

### ប្រការ ១៤ ៖ លក្ខណៈមិនប្រែប្រួលនៃខ្សែព្រំដែន

ក្រោយពីពិធីសារនេះចូលជាធរមាន រាល់ការប្រែប្រួលណាមួយរបស់ភូមិសាស្ត្រផ្លូវទឹកលើដីជាក់ស្ដែងសុទ្ធតែមិនធ្វើឱ្យប្រែប្រួលខ្សែព្រំដែន និងទីតាំងបង្គោលព្រំដែនឡើយ លើកលែងតែករណីដែលភាគីទាំងពីរមានកិច្ចព្រមព្រៀងផ្សេងទៀត។



Media from www.moj.gov.kh resource from www.ocm.gov.kh

## ផ្នែកទី ៤
## បណ្តាប្រការចុងក្រោយ

### ប្រការ ១៥ ៖ តម្លៃផ្លូវច្បាប់នៃពិធីសារ និងបណ្តាឧបសម្ព័ន្ធអម

១-ពិធីសារនេះ គឺជាផ្នែកមួយនៃធាតុផ្សំដែលមិនអាចផ្តាច់ចេញបានពីសន្ធិសញ្ញាឆ្នាំ១៩៨៥ សន្ធិសញ្ញាឆ្នាំ២០០៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩។

២-បណ្តាឧបសម្ព័ន្ធដែលបានលើកឡើងត្រង់ប្រការ ២ ប្រការ ៣ ប្រការ ៦ និងប្រការ ១១ ជាផ្នែកមួយនៃធាតុផ្សំដែលពុំអាចផ្តាច់ចេញពីពិធីសារនេះ។

### ប្រការ ១៦ ៖ បទកំណត់ ស្តីពីការដោះស្រាយទំនាស់

ក្នុងករណីមានភាពខុសគ្នាអំពីការបកស្រាយ និងការអនុវត្តន៍ពិធីសារនេះ ភាគីទាំងពីរនឹងដោះស្រាយដោយសន្តិវិធី សមស្របតាមច្បាប់អន្តរជាតិ។

### ប្រការ ១៧ ៖ សុពលភាព នៃពិធីសារ

ពិធីសារនេះ នឹងត្រូវបានផ្តល់សច្ចាប័ន និងចូលជាធរមាន ចាប់ពីថ្ងៃផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័ន។

ធ្វើនៅហាណូយ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ ជាពីរច្បាប់ ពីរភាសា ភាសាខ្មែរ និងភាសាវៀតណាម។ អត្ថបទទាំងអស់សុទ្ធតែមានតម្លៃស្មើគ្នា ។

| **ជូនមុខ**<br>**ព្រះរាជាណាចក្រកម្ពុជា** | **ជូនមុខ**<br>**សាធារណរដ្ឋសង្គមនិយមវៀតណាម** |
|---|---|
| **វ៉ា គឹមហុង**<br>ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម | **វ៉ៀ ហ្វាយឡុង**<br>អនុរដ្ឋមន្ត្រីក្រសួងការបរទេស និងជាប្រធានគណៈកម្មការចម្រុះខណ្ឌសីមានិងបោះបង្គោលព្រំដែនគោកវៀតណាម-កម្ពុជា |

ឧបសម្ព័ន្ធ១ អមពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក
រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម
PHỤ LỤC 1: ĐÍNH KÈM NGHỊ ĐỊNH THƯ PHÂN GIỚI CẮM MỐC BIÊN GIỚI ĐẤT LIỀN
GIỮA VƯƠNG QUỐC CAMPUCHIA VÀ NƯỚC CHXHCN VIỆT NAM

# ផែនទីឋានលេខាព្រំដែន កម្ពុជា - វៀតណាម

# BẢN ĐỒ ĐỊA HÌNH BIÊN GIỚI CAMPUCHIA - VIỆT NAM

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក កម្ពុជា - វៀតណាម
ỦY BAN LIÊN HỢP PHÂN GIỚI CẮM MỐC BIÊN GIỚI ĐẤT LIỀN CAMPUCHIA - VIỆT NAM

ឆ្នាំ ២០១៩
NĂM 2019

Media from www.moj.gov.kh resource from www.ocm.gov.kh

# ឧបសម្ព័ន្ធ២

អម

ពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក

រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គម

និយមវៀតណាម

# តារាងចុះលេខបង្គោលព្រំដែន

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែន

គោកកម្ពុជា-វៀតណាម

ឆ្នាំ ២០១៩

## តារាងចុះលេខបង្គោល 0/1

| ប្រភេទបង្គោល | វត្ថុធាតុបង្គោល | កាលបរិច្ឆេទបោះបង្គោល |
|---|---|---|
| បង្គោលទោល | បេតុង<br>សរសៃដែក | ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ |

| ទីតាំងបង្គោល | និយាមកា | | រយៈកម្ពស់ (កម្ពស់បង្គោល) (m) |
|---|---|---|---|
| | ក្រឡាចតុរង្គ<br>N (m), E (m) | ភូមិសាស្ត្រ<br>Lat(° ′ ″),Lon(° ′ ″) | |
| បង្គោលលេខ 0/1 បោះនៅលើកំពូលភ្នំ។ | 1624408.88<br>774622.46 | 14 40 45.607<br>107 32 59.819 | 898.32<br>(1.20)<br>**រយៈកម្ពស់ផ្ទៃដី** (m)<br>897.12 |

| ទីតាំង និងចម្ងាយពីបង្គោលមួយទៅបង្គោលមួយ | ប្លង់ទីតាំងបង្គោល |
|---|---|
| មុំអាស៊ីមុតពីចំណុចប្រសព្វនៃខ្សែព្រំដែនទាំងបីប្រទេស កម្ពុជា វៀតណាម ឡាវ ដល់បង្គោលលេខ 0/1 មាន 223°23'07.269" និងមានប្រវែង 1034.17 ម៉ែត្រ។<br>មុំអាស៊ីមុតពីបង្គោលលេខ 0/1 ទៅរកបង្គោលលេខ 0/2 មាន 180°12'17.233" និងមានប្រវែង 691.06 ម៉ែត្រ។ | <br> |



Media from www.moj.gov.kh resource from www.ocm.gov.kh

## តារាងចុះលេខបង្គោល 314

| ប្រភេទបង្គោល | វត្ថុធាតុបង្គោល | កាលបរិច្ឆេទបោះបង្គោល | |
|---|---|---|---|
| បង្គោលទោល ប្រភេទពិសេស | ថ្មក្រានីត | ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២ | |
| ទីតាំងបង្គោល | និយាមកា | | រយៈកម្ពស់ (កម្ពស់បង្គោល) (m) |
| | ក្រឡាចតុរង្គ N(m), E(m) | ភូមិសាស្ត្រ Lat(° ′ ″), Lon(° ′ ″) | |
| បង្គោលលេខ 314 បោះនៅចំណុចចុងបញ្ចប់នៃខ្សែព្រំដែនដីគោក កម្ពុជា-វៀតណាម ។ | 1152295.85<br>438784.25 | 10 25 24.764<br>104 26 26.549 | 7.54<br>(3.00)<br>រយៈកម្ពស់ផ្ទៃដី (m)<br>4.54 |
| ទីតាំង និងចម្ងាយពីបង្គោលមួយទៅបង្គោលមួយ | ប្លង់ទីតាំងបង្គោល | | |
| មុំអាស៊ីមុត ពីបង្គោលលេខ 313/7 ទៅកេបង្គោលលេខ 314 មាន 257°40'48.005" និង មានប្រវែង 186.01 ម៉ែត្រ ។ |  257°40'48.005" 186.01m 313/7 314 | | |



Media from www.moj.gov.kh resource from www.ocm.gov.kh

# ឧបសម្ព័ន្ធ៣

អម

ពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែន
រវាងព្រះរាជាណាចក្រកម្ពុជា និង
សាធារណរដ្ឋសង្គមនិយមវៀតណាម

## តារាងនិយាមការ និង
## រយៈកម្ពស់បង្គោលព្រំដែន

គណៈកម្មការចម្រុះខណ្ឌសីមា និង
បោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
ឆ្នាំ ២០១៩

## តារាងនិយាមកា និងរយៈកម្ពស់បង្គោលព្រំដែន

| លេខសម្គាល់បង្គោល | លេខសន្លឹកផែនទី និងទីតាំងបង្គោល | និយាមកា | | មុំអាស៊ីមុត (° ′ ″) | ចម្ងាយទៅបង្គោលបន្តបន្ទាប់ (m) | លេខបង្គោលបន្តបន្ទាប់ | រយៈកម្ពស់ផ្ទៃដី(m) | ចម្ងាយទៅខ្សែព្រំដែន (m) |
|---|---|---|---|---|---|---|---|---|
| | | ក្រឡាចត្រង្គ N (m), E (m) | ភូមិសាស្ត្រ Lat (°′″),Lon (°′″) | | | | | |
| ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី កម្ពុជា-វៀតណាម-ឡាវ | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1625161.02<br>775331.60 | 14 41 09.800<br>107 33 23.790 | 223 18 52.150 | 1033.73 | 0/1 | 1081.00 | 0 |
| 0/1 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1624408.88<br>774622.46 | 14 40 45.607<br>107 32 59.819 | 180 12 17.233 | 691.06 | 0/2 | 897.12 | 0 |
| 0/2 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1623717.82<br>774619.99 | 14 40 23.137<br>107 32 59.477 | 139 34 03.145 | 787.34 | 0/3 | 916.43 | 0 |
| 0/3 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1623118.52<br>775130.62 | 14 40 03.462<br>107 33 16.306 | 208 33 49.861 | 987.94 | 0/4 | 920.38 | 0 |
| 0/4 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1622250.83<br>774658.25 | 14 39 35.421<br>107 33 00.202 | 173 27 38.070 | 1283.03 | 1 | 903.07 | 0 |
| 1 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1620976.15<br>774804.37 | 14 38 53.918<br>107 33 04.602 | 215 54 43.757 | 401.44 | 1/1 | 902.46 | 0 |
| 1/1 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1620651.02<br>774568.91 | 14 38 43.432<br>107 32 56.616 | 211 02 43.280 | 1375.19 | 1/2 | 871.65 | 0 |
| 1/2 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1619472.81<br>773859.70 | 14 38 05.379<br>107 32 32.488 | 263 48 04.156 | 513.89 | 1/3 | 784.54 | 0 |
| 1/3 | សន្លឹកលេខ 01 ស្ថិតនៅលើខ្សែព្រំដែន | 1619417.32<br>773348.81 | 14 38 03.762<br>107 32 15.405 | 155 40 34.195 | 1014.92 | 1/4 | 804.92 | 0 |
| 1/4 | សន្លឹកលេខ 02 ស្ថិតនៅលើខ្សែព្រំដែន | 1618492.49<br>773766.85 | 14 37 33.536<br>107 32 29.020 | 208 37 38.839 | 747.97 | 2 | 834.92 | 0 |
| 2 | សន្លឹកលេខ 02 ស្ថិតនៅលើខ្សែព្រំដែន | 1617835.96<br>773408.49 | 14 37 12.318<br>107 32 16.807 | 118 54 13.031 | 715.79 | 2/1 | 905.96 | 0 |
| 2/1 | សន្លឹកលេខ 02 ស្ថិតនៅលើខ្សែព្រំដែន | 1617489.99<br>774035.12 | 14 37 00.840<br>107 32 37.604 | 168 03 16.261 | 635.61 | 2/2 | 916.87 | 0 |



Media from www.moj.gov.kh resource from www.ocm.gov.kh

| លេខសម្គាល់បង្គោល | លេខសន្លឹកផែនទី និងទីតាំងបង្គោល | និយាមកា | | មុំអាស៊ីមុត (° ' ") | ចម្ងាយទៅបង្គោលបន្តបន្ទាប់ (m) | លេខបង្គោលបន្តបន្ទាប់ | រយៈកម្ពស់ផ្ទៃដី(m) | ចម្ងាយទៅខ្សែព្រំដែន (m) |
|---|---|---|---|---|---|---|---|---|
| | | ក្រឡាចត្រង្គ N (m), E (m) | ភូមិសាស្ត្រ Lat (°' "),Lon (°' ") | | | | | |
| 313/5 | សន្លឹកលេខ ១២ ស្ថិតនៅលើខ្សែព្រំដែន | 1152412.66<br>439318.04 | 10 25 28.598<br>104 26 44.099 | 257 36 26.869 | 184.24 | 313/6 | 1.81 | 0 |
| 313/6 | សន្លឹកលេខ ១២ ស្ថិតនៅលើខ្សែព្រំដែន | 1152373.12<br>439138.09 | 10 25 27.300<br>104 26 38.183 | 257 40 58.280 | 176.17 | 313/7 | 1.86 | 0 |
| 313/7 | សន្លឹកលេខ ១២ ស្ថិតនៅលើខ្សែព្រំដែន | 1152335.54<br>438965.98 | 10 25 26.067<br>104 26 32.524 | 257 40 48.005 | 186.01 | 314 | 2.03 | 0 |
| 314 | សន្លឹកលេខ ១២ ស្ថិតនៅលើខ្សែព្រំដែន | 1152295.85<br>438784.25 | 10 25 24.764<br>104 26 26.549 | | | | 4.54 | 0 |



Media from www.moj.gov.kh resource from www.ocm.gov.kh

# ឧបសម្ព័ន្ធ ៤

អម

ពិធីសារខណ្ឌសីមា និងបង្គោលព្រំដែនគោក
រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

## តារាងរាយនាមកម្មសិទ្ធិដីកោះ នៅតាមខ្សែព្រំដែនផ្លូវទឹក

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែន
គោកកម្ពុជា-វៀតណាម
ឆ្នាំ ២០១៩

# តារាងរាយនាមកម្មសិទ្ធិដីកោះ នៅតាមព្រំដែនផ្លូវទឹក

******

<table>
<tr><th rowspan="2">លេខរៀងផ្លូវទឹក</th><th rowspan="2">លេខរៀងដីកោះ</th><th rowspan="2">កម្មសិទ្ធិរបស់ប្រទេស</th><th colspan="2">និយាមកាភូមិសាស្ត្រ</th><th rowspan="2">ស្ថិតក្នុងផ្ទាំងផែនទីលេខ</th><th rowspan="2">ស្ថិតនៅកំណាត់ព្រំដែនពីបង្គោលដល់បង្គោល</th></tr>
<tr><th>Lat (° ′ ″),Lon (° ′ ″)</th><th>Lat (° ′ ″),Lon (° ′ ″)</th></tr>
<tr><td>១</td><td colspan="6">ពីបង្គោលលេខ 10-11<br>អូរគ្មានឈ្មោះ គឺជាព្រំដែនផ្លូវទឹកមិនអាចធ្វើនាវាចរបាន មានប្រវែង ៥.០៩២ គីឡូម៉ែត្រ មិនមានដីកោះបែងចែកកម្មសិទ្ធិ</td></tr>
<tr><td>២</td><td colspan="6">ពីបង្គោលលេខ 23-24<br>អូរគ្មានឈ្មោះ គឺជាព្រំដែនផ្លូវទឹកមិនអាចធ្វើនាវាចរបាន មានប្រវែង ៩.០២៣ គីឡូម៉ែត្រ មិនមានដីកោះបែងចែកកម្មសិទ្ធិ</td></tr>
<tr><td rowspan="4">៣</td><td colspan="6">ពីបង្គោលលេខ 24-25<br>ព្រែកសាចី គឺជាព្រំដែនផ្លូវទឹកមិនអាចធ្វើនាវាចរបាន មានប្រវែង ៩.២៤២ គីឡូម៉ែត្រ មានដីកោះចំនួន ០៣ បែងចែកកម្មសិទ្ធិរួមមាន៖</td></tr>
<tr><td>1</td><td>កម្ពុជា</td><td>13°55'37.416"</td><td>107°27'26.927"</td><td>12</td><td>24/5-25</td></tr>
<tr><td>2</td><td>កម្ពុជា</td><td>13°55'33.656"</td><td>107°27'26.107"</td><td>12</td><td>24/5-25</td></tr>
<tr><td>3</td><td>វៀតណាម</td><td>13°55'32.273"</td><td>107°27'30.875"</td><td>12</td><td>24/5-25</td></tr>
</table>



Media from www.moj.gov.kh resource from www.ocm.gov.kh

| លេខរៀងផ្លូវទឹក | លេខរៀងដីកោះ | កម្មសិទ្ធិរបស់ប្រទេស | និយាមកាភូមិសាស្ត្រ | | ស្ថិតក្នុងផ្ទាំងផែនទីលេខ | ស្ថិតនៅកំណាត់ព្រំដែនពីបង្គោលដល់បង្គោល |
|---|---|---|---|---|---|---|
| | | | Lat (° ′ ″),Lon (° ′ ″) | Lat (° ′ ″),Lon (° ′ ″) | | |
| ៣៣ | ពីបង្គោលលេខ 308/4-309<br>ប្រឡាយគ្មានឈ្មោះ គឺជាព្រំដែនផ្លូវទឹកមិនអាចធ្វើនាវាចរបាន មានប្រវែង ០.០៧១ គីឡូម៉ែត្រ មិនមានដីកោះបែងចែកកម្មសិទ្ធិ | | | | | |
| ៣៤ | ពីបង្គោលលេខ 309-310<br>ព្រែកស្លាកខ្មៅ(គ្មានឈ្មោះ) គឺជាព្រំដែនផ្លូវទឹកមិនអាចធ្វើនាវាចរបាន មានប្រវែង ០.៣១៤ គីឡូម៉ែត្រ មិនមានដីកោះបែងចែកកម្មសិទ្ធិ | | | | | |

- មាន ៣៤ កំណាត់ព្រំដែនផ្លូវទឹកក្នុងនោះមាន ៖
  - + ០៧ កំណាត់ផ្លូវទឹក អាចធ្វើនាវាចរបាន
  - + ២៧ កំណាត់ផ្លូវទឹក មិនអាចធ្វើនាវាចរមិនបាន
- មាន ០៦ កំណាត់ផ្លូវទឹក អាចធ្វើនាវាចរបាន មានដីកោះបែងចែកកម្មសិទ្ធិសរុប ១០៥ ដីកោះ ក្នុងនោះ ៖
  - + ៦១ ដីកោះកម្មសិទ្ធិ កម្ពុជា
  - + ៤៤ ដីកោះកម្មសិទ្ធិ វៀតណាម





Media from www.moj.gov.kh resource from www.ocm.gov.kh

10/05/2021

# ឧបសម្ព័ន្ធ ៥

អម

ពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក រវាង

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម

## តារាងបញ្ជីកំណាត់ព្រំដែន

## ដែលពុំទាន់ធ្វើបញ្ចប់ការខណ្ឌសីមា និងបោះបង្គោលព្រំដែន

គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម

ឆ្នាំ ២០១៩

Media from www.moj.gov.kh resource from www.ocm.gov.kh

## តារាងបញ្ជីកំណាត់ព្រំដែន
## ដែលពុំទាន់ធ្វើបញ្ចប់ការខណ្ឌសីមា និងបោះបង្គោលព្រំដែន

| ល.រ | ខេត្តជាប់ព្រំប្រទល់ | កំណាត់ព្រំដែន | ស្ថិតនៅផ្ទាំងផែនទីមាត្រដ្ឋាន ១/២៥ ០០០ |
|---|---|---|---|
| ១ | រតនគិរី-កន់ទុំ | ពីបង្គោលលេខ២២/១ ដល់ទីតាំងបង្គោលលេខ២៣(១,២) | ផ្ទាំងលេខ១១ |
| ២ | រតនគិរី-យ៉ាឡាយ | ពីទីតាំងបង្គោលលេខ២៥/៣(១,២) ដល់ទីតាំងបង្គោលលេខ២៥/៤(១,២)<br>ពីបង្គោលលេខ៣០ ដល់បង្គោលលេខ៤០<br>ពីបង្គោលលេខ៤០ ដល់បង្គោលលេខ៤១ | ផ្ទាំងលេខ១៣ ១៤<br>ផ្ទាំងលេខ១៤ ១៥ ១៦ ១៧ ១៨ ១៩<br>ផ្ទាំងលេខ១៩ |
| ៣ | មណ្ឌលគិរី-ដាក់ឡាក់ | ពីបង្គោលលេខ៤១ ដល់បង្គោលលេខ៤២<br>ពីបង្គោលលេខ៤២ ដល់បង្គោលលេខ៤៣<br>ពីបង្គោលលេខ៤៣ ដល់បង្គោលលេខ៤៤ | ផ្ទាំងលេខ១៩ ២០<br>ផ្ទាំងលេខ២០ ២១<br>ផ្ទាំងលេខ២១ |
| ៤ | មណ្ឌលគិរី-ដាក់ណុង | ពីបង្គោលលេខ៥៥/៨ដល់ទីតាំងបង្គោលលេខ៦០/១(១,២) | ផ្ទាំងលេខ៣០ ៣១ ៣៧ |
| ៥ | ត្បូងឃ្មុំ-ប៊ិញភឿក | ពីបង្គោលលេខ៧៥/៧ ដល់បង្គោលលេខ៧៥/៨<br>ពីបង្គោលលេខ៧៥/៨ ដល់បង្គោលលេខ៧៥/៩<br>ពីទីតាំងបង្គោលលេខ៧៥/២(១,២) ដល់ទីតាំងបង្គោលលេខ៧៧/៣(១,២) | ផ្ទាំងលេខ៤៥ ៤៦<br>ផ្ទាំងលេខ៤៦<br>ផ្ទាំងលេខ៤៦ |
| ៦ | ស្វាយរៀង-តៃនិញ | ពីបង្គោលលេខ១៣៨ ដល់បង្គោលលេខ១៤៦<br>ពីបង្គោលលេខ១៦៨ ដល់បង្គោលលេខ១៦៨/១ | ផ្ទាំងលេខ៥៧ ៥៨<br>ផ្ទាំងលេខ៦៣ ៦៤ |



Media from www.moj.gov.kh resource from www.ocm.gov.kh

| | | | |
|---|---|---|---|
| | | ពីបង្គោលលេខ១៦៨/១ ដល់បង្គោលលេខ១៦៨/២<br>ពីបង្គោលលេខ១៦៨/២ ដល់បង្គោលលេខ១៦៩ | ផ្ទាំងលេខ៦៤<br>ផ្ទាំងលេខ៦៤ |
| ៧ | ស្វាយរៀង-ឡុងអាន | ពីបង្គោលលេខ១៨៣ ដល់បង្គោលលេខ១៨៩<br>ពីបង្គោលលេខ១៩២ ដល់បង្គោលលេខ១៩៤<br>ពីបង្គោលលេខ២០៣ដល់ទីតាំងបង្គោលលេខ២០៨/១(១,២)<br>ពីទីតាំងបង្គោលលេខ២១០(១,២)ដល់បង្គោលលេខ២១៦(១)<br>ពីបង្គោលលេខ២២០ ដល់បង្គោលលេខ២២១<br>ពីបង្គោលលេខ២២៧ ដល់ទីតាំងបង្គោលលេខ២២៩/១(១,២) | ផ្ទាំងលេខ៦៥<br>ផ្ទាំងលេខ៦៦<br>ផ្ទាំងលេខ៦៧ ៦៨ ៦៩<br>ផ្ទាំងលេខ៧០ ៧១<br>ផ្ទាំងលេខ៦៩<br>ផ្ទាំងលេខ៧២ ៧៣ |
| ៨ | កណ្ដាល-អានយ៉ាង | ពីបង្គោលលេខ២៤១ ដល់ទីតាំងបង្គោលលេខ២៤៥/១(១,២)<br>ពីទីតាំងបង្គោលលេខ២៤៦/៣(១,២) ដល់ទីតាំងព្រាងបោះបង្គោលលេខ២៥៣ | ផ្ទាំងលេខ៨១<br>ផ្ទាំងលេខ៨៣ |
| ៩ | តាកែវ-អានយ៉ាង | ពីទីតាំងព្រាងបោះបង្គោលលេខ២៥៣ ដល់បង្គោលលេខ២៥៤<br>ពីបង្គោលលេខ២៦៦/១ ដល់បង្គោលលេខ២៦៦/២ | ផ្ទាំងលេខ៨៣<br>ផ្ទាំងលេខ៨៥ |
| ១០ | កំពត-កៀនយ៉ាង | ពីបង្គោលលេខ២៩៥ ដល់បង្គោលលេខ៣០១ | ផ្ទាំងលេខ៨៩ ៩០ |



Media from www.moj.gov.kh resource from www.ocm.gov.kh